# បញ្ជីត្រួតពិនិត្យ

## បទដ្ឋានអប្បបរមា ដើម្បីបង្កើតទីកន្លែង **ចត្តាឡីស័ក** ប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាជនដែលងាយរងគ្រោះដូចជា ស្ត្រី កុមារ និងក្មេងជំទង់ និងប្រជាជន វ័យចំណាស់

## ១. គោលបំណងនៃបញ្ជីត្រួតពិនិត្យនេះ

- នេះគឺជាបញ្ជីសកម្មភាព និងវិធាន ជាអនុសាសន៍ ដែលអាចអនុវត្តនៅពេលបង្កើតទីកន្លែងចត្តាឡីស័ក ដើម្បីធានាសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរបស់ ស្ត្រី កុមារ ក្មេងជំទង់ និងប្រជាជន វ័យចំណាស់ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃវីរុសកូវីដ-១៩។

- ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងមហាផ្ទៃ និង គណៈកម្មាធិការឆ្លើយតបចំពោះវីរុសកូវីដ-១៩ នៅថ្នាក់ក្រោមជាតិ អាចប្រើប្រាស់បញ្ជីត្រួត ពិនិត្យនេះ នៅពេលកំពុងអនុវត្ត ឬគ្រោងនឹងបង្កើត និងគ្រប់គ្រងទីកន្លែងចត្តាឡីស័កសម្រាប់ករណីកូវីដ-១៩។

- តាមគោលការណ៍ អ្នកដែលត្រូវបានដាក់នៅក្នុងទីកន្លែងចត្តាឡីស័កបណ្តោះអាសន្ន នឹងមិនត្រូវបានចាត់ទុកជាអ្នកជាប់ឃុំនោះទេ។ ផ្តល់ព័ត៌មានទាក់ទងនឹងហេតុផលដែលតម្រូវឱ្យពួកគាត់ធ្វើ ចត្តាឡីស័ក និងសិទ្ធិរបស់ពួកគាត់។



# ២. បញ្ជីអនុសាសន៍

## ២.១ មុខងារគ្រប់គង

- ធានាថា មានចំនួនស្ត្រី និងបុរសស្មើគ្នាក្នុងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលចត្តាឡីស័ក និងធានាថា ស្ត្រីមានការចូលរួមស្មើៗគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
- ធានាថា អ្នកផ្តល់សេវាដែលត្រូវបានដាក់ពង្រាយ ដើម្បីគ្រប់គ្រងនិងប្រតិបត្តិការសេវាកម្ម មានស្ត្រី និងបុរស ដូច្នេះអ្នកដែលនៅក្នុងចត្តាឡីស័ក (ស្ត្រី បុរស និងអ្នកផ្សេងទៀតទទួលបានអារម្មណ៍ផាសុកភាពជាងមុនក្នុងការទាក់ទងទៅអ្នកផ្តល់សេវា នៅពេលពួកគេត្រូវការការគាំទ្រណាមួយ។
- ធានាថា រាល់វិធានការសំរាប់ការគ្រប់គ្រងទីកន្លែងចត្តាឡីស័កឆ្លុះបញ្ចាំងពីតំរូវការផ្សេងៗគ្នារបស់ស្ត្រី និងបុរសក៏ដូចជាកុមារ។
- ធានាថា មានការពិនិត្យតាមដាន ក៏ដូចជាយន្តការត្រួតពិនិត្យតាមកាលកំណត់ច្បាស់លាស់ នៅតាមទីចត្តាឡីស័កនីមួយៗដើម្បីធានាថា បុគ្គលដែលនៅទីនោះ ទទួលបានការថែទាំការព្យាបាលនិងសេវាកម្មបានត្រឹមត្រូវ និងទាន់ពេលវេលា។
- នៅពេលកត់សម្គាល់ឃើញថា ការសួរសុខទុក្ខត្រូវបានរឹតត្បិតដោយសារតែការព្រួយបារម្ភទាក់ទងនឹងសុខភាព អ្នកគ្រប់គ្រងទីកន្លែងចត្តាឡីស័កត្រូវធានាឱ្យមានមធ្យោបាយគ្រប់គ្រាន់សម្រាប់អ្នកដែលនៅក្នុងចត្តាឡីស័កអាចរក្សាទំនាក់ទំនងជាមួយគ្រួសារសាច់ញាតិនិងមិត្តភក្តិរបស់ពួកគេ
- ឧទាហរណ៍តាមទូរស័ព្ទអ៊ិនធឺណិត /អ៊ីម៉ែលនិងមធ្យោបាយសមស្របផ្សេង ទៀត។ វាគួរតែត្រូវបានសម្របសម្រួលដោយឥតគិតថ្លៃ។

## ២.២ សុវត្ថិភាព និងសន្តិសុខ

- ធានាយ៉ាងណាឱ្យស្ត្រី និងបុរសស្នាក់នៅក្នុងបន្ទប់ដាច់ដោយឡែកពីគ្នា ឬនៅកន្លែងដាច់ដោយឡែកពីគ្នា ដោយមានរាំងននឬរបាំងខណ្ឌចែក ពួកគេស្របតាមនីតិវិធី របស់ក្រសួងសុខាភិបាលនិងអង្គការសុខភាពពិភពលោកស្តីពីការរក្សាគម្លាតសុវត្ថិភាព។

- ធានាថា កុមារ និងក្មេងជំទង់ស្នាក់នៅរួមគ្នាជាមួយនឹងឪពុកម្តាយ សាច់ញាតិ អ្នកផ្តល់ការថែទាំដទៃទៀតរបស់ពួកគេដោយមានការផ្តល់ដំបូន្មានជាក់លាក់ពីវេជ្ជបណ្ឌិត ដើម្បីការពារ មិនឱ្យឆ្លងវីរុសកូវីដ-១៩។

- កុមារដែលបែកគ្នា ឬមិនមានឪពុកឬម្តាយនៅអមជាមួយគួរមានបុគ្គលិកសង្គមម្នាក់ដែលអាចជួយផ្តល់ការគាំទ្រដល់កុមារគ្រប់ពេលវេលាក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ជួយសម្របសម្រួលក្នុងការធ្វើការទំនាក់ទំនងជាមួយគ្រួសារ និងពេលដែលជួបជុំគ្រួសារវិញ។

- កុមារទាំងអស់ដែលស្ថិតនៅទីកន្លែងចត្តាឡីស័កត្រូវទទួលបានការគាំទ្រដោយបុគ្គលិកសង្គម ដែលជួយកុមារ ក្នុងការទទួលបានការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គមតាមតម្រូវការ។

- ធានាថា បន្ទប់គេងទាំងអស់មានទ្វារ និងបង្អួចនិងមានសោរចាក់ពីខាងក្នុង។

- ផ្តល់ភ្លើងបំភ្លឺគ្រប់គ្រាន់នៅកន្លែងដែលប្រើប្រាស់រួមគ្នា (ដូចជារានហាល ទីវាលខាងក្រៅ ច្រកចេញចូល... ជាដើម)។

- ធានាថា បង្គន់អនាម័យ កន្លែងលាងសម្អាតដៃនិងកន្លែងងូតទឹកមានការរក្សាឯកជនភាព និងផ្តល់សន្តិសុខ សុវត្ថិភាពគ្រប់គ្រាន់ដល់ស្ត្រី កុមារី និងក្មេងស្រីជំទង់ ដូចជា៖

- នៅកៀក ឬនៅជាប់ជាមួយនឹងបន្ទប់ ឬកន្លែងដែលពួកគេគេង
- នៅដោយឡែកពីកន្លែងសម្រាប់បុរស
- មិននៅកៀក ឬត្រូវដើរកាត់បន្ទប់របស់បុរស
- មានគន្លឹះ និងសោរពីខាងក្នុង
- មានភ្លើងបំភ្លឺគ្រប់គ្រាន់
- ការផ្តល់ចំនួនសម្ភារៈនិងឧបករណ៍ការពារស្មើៗគ្នាដល់ស្ត្រីនិងបុរស

- ធានាថា កន្លែងដែលប្រើប្រាស់ដោយកុមារ និងក្មេងជំទង់មានសុវត្ថិភាព និងអាចធ្វើការពិនិត្យ តាមដានបានជាប់ជានិច្ច។
- ធានាថា កុមារ និងក្មេងជំទង់ដែលពុំមានអាណាព្យាបាលនៅអមជា មួយ ទទួលបានការការពារ និងការថែទាំគ្រប់គ្រាន់ពីបុគ្គលិកក្នុងមណ្ឌល ចត្តាឡីស័ក និងមានការសម្របសម្រួលឱ្យពួកគេបានទំនាក់ទំនងទៅកាន់ ឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។
- ធានាឱ្យមានការអនុវត្តវិធានសុវត្ថិភាព សម្រាប់ជនមានពិការភាពដូចជាមាន ភ្លើងបំភ្លឺគ្រប់គ្រាន់ និងអ្នកដែលប្រើរទេះអាចធ្វើដំណើរទៅបន្ទប់ទឹកកន្លែង សម្អាតខ្លួន ឬងូតទឹក។

## ២.៣ សុខភាព អាហារូបត្ថម្ភ អនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួន



- ធានាឱ្យមានការទទួលបានទឹកស្អាតឱ្យបានគ្រប់គ្រាន់ បង្គន់អនាម័យ និងកន្លែងងូតទឹកដែលស្អាត ងាយស្រួលប្រើប្រាស់និងអាចប្រើប្រាស់បាន

ព្រមទាំងធុងសំរាមមានគម្របបិទជិត ដើម្បីរក្សាអនាម័យដល់ស្ត្រីកុមារ និងក្មេងជំទង់។

- ធានាថា ស្ត្រី និងក្មេងស្រី ទទួលបានឧបករណ៍ការពារខ្លួនស្របតាម អនុសាសន៍ ដែលផ្តល់ឱ្យ។
- ធានាថា ស្ត្រី និងក្មេងស្រីបានទទួលកញ្ចប់អនាម័យគ្រប់គ្រាន់ ដូចជា សំឡី អនាម័យ និងសាប៊ូ ឬទឹកលាងសម្អាតដៃជាដើម។
- ធានាថា ស្ត្រីមានផ្ទៃពោះ អាចទទួលបានការសម្រាលកូននៅកន្លែងដែល ស្អាត និងមានសុវត្ថិភាព ជាពិសេស ទទួលបានការព្យាបាលក្នុងករណី ដែលមានផលវិបាកពេលមានផ្ទៃពោះ។
- គួរមានការផ្តល់ការប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយ ការគាំទ្រ ចិត្តសង្គមជាមូលដ្ឋាន និងគាំទ្រសម្រាប់ការផ្តល់អាហារសមស្របដល់ ស្ត្រីមានផ្ទៃពោះ និងម្តាយដែលមានកូនជាទារក និងកុមារតូច មិនថាពួកគេ ឬទារក និងកូនតូចៗរបស់ពួកគេ ត្រូវបានសង្ស័យថា មានវីរុស កូវីដ-១៩ ឬត្រូវបញ្ជាក់ថាមានវីរុសកូវីដ-១៩ នោះទេ។
- ទារកដែលកើតចេញពីម្តាយ ដែលសង្ស័យ ឬអាចមានវីរុសកូវីដ១៩ ឬត្រូវ បានបញ្ជាក់ថាមានវីរុសកូវីដ-១៩ គួរទទួលបានអាហារស្របតាម គោលការណ៍ណែនាំស្តង់ដារ ស្តីពីការផ្តល់អាហារដល់ទារកហើយក្នុងពេល ជាមួយគ្នា ត្រូវមានការអនុវត្តបម្រុងប្រយ័ត្នដែលចាំបាច់នានា សម្រាប់បង្ការ និងត្រួតពិនិត្យការឆ្លងរោគ។នៅក្នុងស្ថានភាពដែលម្តាយមានជំងឺធ្ងន់ធ្ងរ ដែលធ្វើឱ្យគាត់មិនអាចផ្តល់ការថែទាំដល់កូនរបស់គាត់បាន ឬមិនអាចឱ្យ គាត់បន្តបំបៅកូនដោយផ្ទាល់គួរមានការលើកទឹកចិត្ត និងជួយដល់ម្តាយឱ្យ ច្របាច់ទឹកដោះទុក និងផ្តល់ទឹកដោះម្តាយដែលច្របាច់ទុកនេះដល់ទារក ប្រកបដោយសុវត្ថិភាពហើយក្នុងពេលជាមួយគ្នា ត្រូវមានការអនុវត្តវិធានការ សមស្រប ដើម្បីបង្ការ និងត្រួតពិនិត្យការឆ្លងរោគ។

- ធានាថា ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅកូន និងកុមារតូចជាពិសេសកុមារអាយុចន្លោះពី ៦ ដល់ ២៣ ខែ បានទទួលរបបអាហារសមស្របគ្រប់គ្រាន់ទាំងបរិមាណ ទាំងគុណភាព។
- ធានាឱ្យមានការរៀបចំកន្លែងដែលមានសុវត្ថិភាព និងរក្សាបាននូវភាពឯកជនដើម្បីឱ្យម្តាយអាចបំបៅកូនរបស់ពួកគេបាន។
- ធានាថា មានសេវាគាំទ្រសុខភាពផ្លូវចិត្ត និងការគាំទ្រផ្នែកចិត្តសាស្ត្រដល់អ្នកដែលត្រូវការ ទាំងក្នុងកំឡុងពេល និងក្រោយពេលនៃការធ្វើចត្តាឡីស័ក។
- ធានាឱ្យបាននូវសកម្មភាព ធ្វើការហាត់ប្រាណ និងគាំទ្រសុខភាពផ្លូវចិត្ត នៅនឹងកន្លែងចត្តាឡីស័កដើម្បីឱ្យអ្នកដែលត្រូវបានដាក់នៅទីនោះអាចគ្រប់គ្រងការថប់បារម្ភ និងបញ្ហាផ្លូវចិត្ត។ ទាំងនេះអាចធ្វើទៅបានតាមរយៈការចូលរួមរបស់មនុស្សដែលនៅក្នុងទីកន្លែងចត្តាឡីស័ក។
- ធានាថា បុគ្គលដែលមានជំងឺប្រចាំកាយ ឬបញ្ហាសុខភាពដែលមានស្រាប់អាចទទួលបានថ្នាំព្យាបាលប្រចាំថ្ងៃរបស់ពួកគេ រួមទាំងស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍។
- ធានាឱ្យមានការផ្សព្វផ្សាយព័ត៌មានអំពីវីរុសកូវីដ-១៩ និងសេវានានាដែលផ្តល់ដោយអាជ្ញាធររដ្ឋាភិបាល និងដៃគូពាក់ព័ន្ធសំខាន់ៗដទៃទៀតបានដឹងឮដល់គ្រប់គ្នា ដូចជា ត្រូវប្រើប្រាស់  រូបភាព និងភាសាសាមញ្ញៗសម្រាប់ក្រុមគោលដៅផ្សេងៗគ្នាជាដើម។
- ផ្តល់ព័ត៌មានដល់ ស្ត្រី កុមារ និងក្មេងជំទង់ អំពីវិធានការដែលកំពុងដាក់ឱ្យអនុវត្ត ដើម្បីធានាសុវត្ថិភាព និងសន្តិសុខ នៅតាមទីកន្លែងចត្តាឡីស័ករួមទាំងរបៀបរាយការណ៍ពីករណីបៀតបៀតផ្លូវភេទ និងអំពើហិង្សាផ្លូវភេទភ្ជាប់ជាមួយអ្នកដែលទទួលបន្ទុកទទួលការរាយការណ៍។
- ផ្តល់ព័ត៌មានអំពីខ្សែទូរស័ព្ទផ្តល់ជំនួយ និងយន្តការគាំទ្រដទៃទៀតដែលមានសម្រាប់ស្ត្រី កុមារ និងក្មេងជំទង់។

- ធានាថា បុគ្គលិកទាំងអស់ដែលធ្វើការងារនៅទីកន្លែងចត្តាឡីស័កមានពាក់ឯកសណ្ឋាន និងផ្លាកឈ្មោះ ដើម្បីឱ្យគេងាយស្រួលសម្គាល់ដឹងបានច្បាស់។
- ធានាឱ្យមានការផ្តល់សេវាបកប្រែឯកសារ ឬបកប្រែផ្ទាល់មាត់នៅតាមមណ្ឌលចត្តាឡីស័ក (អ្នកបកប្រែតាមប្រព័ន្ធអនឡាញឬអ្នកបកប្រែភាសាសញ្ញាគរថ្លង់)។

## ២.៥ បង្ការអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ការបៀតបៀនផ្លូវភេទនិងការរំលោភបំពាន



- ធានាថា អ្នកគ្រប់គ្រងទីកន្លែងចត្តាឡីស័កបានទទួលការបណ្តុះបណ្តាលពីរបៀបឆ្លើយតបលើ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនិងអំពើហិង្សាលើផ្លូវភេទនិងពីការទប់ស្កាត់ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទ។
- ធានាថា បុគ្គលិកទាំងអស់ បានយល់ស្របអនុវត្តតាមក្រមសីលធម៌និងមានចំណេះដឹង ជាមូលដ្ឋាន ស្តីពីការបង្ការអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ។

ខិតខំប្រឹងប្រែងធានាយ៉ាងណាឱ្យបុគ្គលដែលត្រូវបានធ្វើចត្តាឡីស័កបានទទួលការថែទាំពីភ្នាក់ងារសុខាភិបាល និងអ្នកផ្តល់សេវាគាំទ្រដែលមានភេទដូចពួកគេ។ធានាថាកុមារត្រូវបានទទួលការមើលថែទាំ ដោយយកចិត្តទុកដាក់ក្នុងកំឡុងពេលពិនិត្យសុខភាពហើយឪពុកម្តាយរបស់គាត់ឬអ្នកមើលថែត្រូវតែមានវត្តមានក្នុងកំឡុងពេលពិនិត្យ។ខិតខំប្រឹងប្រែងធានាយ៉ាងណាឱ្យមានវត្តមានមន្ត្រីសន្តិសុខជាស្ត្រីនៅកន្លែងចត្តាឡីស័កសម្រាប់ស្ត្រីកុមារនិងក្មេងជំទង់។ ផ្តល់កន្លែងដែលមានសុវត្ថិភាពសម្រាប់ពេលមានអាសន្នដោយមានបុគ្គលិកជំនាញដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ

ដើម្បីឱ្យស្ត្រីនិងកុមារអាចទៅបានប្រសិនបើពួកគេប្រឈមនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រការបៀតបៀនផ្លូវភេទនិងការរំលោភបំពានក្នុងមណ្ឌលចត្តាឡីស័ក។

- ចាត់តាំងឱ្យមានអ្នកគ្រប់គ្រងម្នាក់ ឬអ្នកសម្របសម្រួលម្នាក់នៅក្នុងមណ្ឌលចត្តាឡីស័ក ដែលទទួលខុសត្រូវលើការទទួលការរាយការណ៍ពីស្ត្រី និងកុមារអំពីករណីអំពើហិង្សាការបៀតបៀនផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ។
- ធានាថាអ្នកគ្រប់គ្រងនេះ បានទទួលការបណ្តុះបណ្តាលអំពីការទទួលពាក្យបណ្តឹងដោយមានការគោរពការសម្ងាត់និងប្រើប្រាស់វិធីសាស្ត្រដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនិងមានការយល់ដឹងអំពីយន្តការបញ្ជូននិងយន្តការការពារដែលត្រូវអនុវត្ត។
- ធានាថា យន្តការនៃការរាយការណ៍ប្រកាន់ខ្ជាប់នូវគោលការណ៍ស្នូលនៃការរាយការណ៍ដែលមានប្រសិទ្ធភាពរួមមានសុវត្ថិភាពការសម្ងាត់មានតម្លាភាពនិងភាពងាយស្រួល។
- ការពារអត្តសញ្ញាណ និងសុវត្ថិភាពរបស់អ្នកដែលរងអំពើហិង្សា។សូមកុំសរសេរ ថតរូប ឬនិយាយផ្ទាល់មាត់នូវព័ត៌មានផ្ទាល់ខ្លួន/អត្តសញ្ញាណណាមួយរបស់អ្នកដែលរងអំពើហិង្សាឬបទពិសោធន៍របស់ពួកគេរួមទាំងការចែករំលែកទៅដល់អ្នកគ្រប់គ្រងរបស់អ្នក។
- ធានាថា បុគ្គលដែលរាយការណ៍ពីករណីកេងប្រវ័ញ្ចផ្លូវភេទឬការរំលោភបំពានផ្លូវភេទ ត្រូវបានបញ្ជូនទៅរកអ្នកផ្តល់សេវាឆ្លើយតបចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ដើម្បីតាមដាននិងទទួលបានការគាំទ្របន្ថែមទៀត។
- រៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានសំខាន់ៗ(ខិត្តប័ណ្ណផ្ទាំងរូបភាព។ល។) ជាភាសាខ្មែរ ភាសាអង់គ្លេសនិងភាសាជនជាតិដើមភាគតិចសម្រាប់ស្ត្រីនិងកុមារ ក៏ដូចជា ព័ត៌មានសម្រាប់ជនមានពិការភាពដោយមានកាផ្តល់លេខទូរស័ព្ទ របស់មន្ត្រីដែលទទួលខុសត្រូវលើមណ្ឌលចត្តាឡីស័កនិងខ្សែទូរស័ព្ទ

រាយការណ៍ព័ត៌មាននិងខ្សែទូរស័ព្ទផ្ដល់ជំនួយ (រួមនឹងខ្សែទូរស័ព្ទរបស់ស្ថានទូតបរទេស)ដែលពួកគេអាចហៅទៅដើម្បីទទួលបានការគាំទ្រ ប្រសិន បើពួកគេជួបប្រទះនឹងករណីអំពើហិង្សាការបៀតបៀនផ្លូវភេទឬការរំលោភបំពាន។

## ២.៦ ទិន្នន័យ និងឯកសារ

- ព័ត៌មានអំពីការគ្រប់គ្រងករណី គួរតែរក្សាទុកឱ្យមានសុវត្ថិភាពនិងធានាការសម្ងាត់។
- ព័ត៌មានមូលដ្ឋានខាងក្រោមរបស់កុមារដែលមិនមានគ្រួសារឬមិនមានឪពុកម្ដាយអមជាមួយ ត្រូវរក្សាជាការសម្ងាត់។ នេះរួមមាន៖
    - ឈ្មោះរបស់កុមារ
    - អាយុរបស់កុមារ
    - ភេទរបស់កុមារ
    - អ្នកដែលកុមារ រស់នៅជាមួយ និងអាសយដ្ឋានរបស់ពួកគេ(បើមាន)
    - ឈ្មោះ និងលេខទំនាក់ទំនង អាស័យដ្ឋានផ្ទះរបស់មនុស្សពេញវ័យដែលមកជាមួយកុមារ (បើមាន)
    - ឈ្មោះរបស់ជនបង្គោលរបស់ភ្នាក់ងារដែលទទួលទុកព័ត៌មានរបស់កុមារ។

សហការជាមួយៈ

ក្រសួងសុខាភិបាល

គាំទ្រដោយៈ

USAID FROM THE AMERICAN PEOPLE

unicef for every child

UN WOMEN

UNFPA

UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER Cambodia

Save the Children